ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៧ សហវ.-ទន

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ... ឆ្នាំ២០០៥

## សារាចរណែនាំ
### ស្តីពី
### ការអនុវត្តន៍ប្រកាសស្តីពីការបន្តរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញពីរឆ្នាំ ចំពោះសហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញ

អនុវត្តន៍តាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គបើកទូលាយ កាលពីថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៥ ដើម្បីជាកិច្ចគាំពារដល់សហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញ ក្នុងនោះមាន រោងចក្រវាយនភ័ណ្ឌ រោងចក្រកាត់ដេរ និងរោងចក្រផលិតស្បែកជើង ឱ្យមានលទ្ធភាពឆ្លងផុតដំណាក់កាលផុតភាពអនុគ្រោះផ្នែកពន្ធដារសម្រាប់ទីផ្សារសហរដ្ឋអាមេរិក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៣០២ សហវ.ប្រក.ពដ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ បន្តរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញពីរឆ្នាំបន្ថែមទៀតដល់សហគ្រាសទាំងនេះ ។ ដើម្បីអនុវត្តខ្លឹមសារនៃប្រកាសខាងលើនេះឱ្យមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោមនេះ :

១. សហគ្រាសដែលផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៦ ត្រូវបានអនុញ្ញាតបន្តរយៈពេលលើកលែងពន្ធនេះចំនួនពីរឆ្នាំទៀត ដោយគិតចាប់ពីថ្ងៃផុតសុពលភាពនៃការលើកលែងលើកដំបូង ។ សហគ្រាសដែលបានទទួលការអនុញ្ញាតិពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបន្តរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញម្តងរួចហើយ មិនត្រូវបានអនុញ្ញាតបន្តការលើកលែងទៀតទេ ។

២. ប្រសិនបើសហគ្រាសដូចបានចែងក្នុងចំណុច១ខាងលើបានបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញនាក្រោយថ្ងៃផុតសុពលភាពនៃការលើកលែងពន្ធលើប្រាក់ចំណេញដំបូង ប្រាក់រំដោះពន្ធលើប្រាក់ចំណេញនេះនឹងត្រូវបានអនុញ្ញាតជាឥណទាន សម្រាប់កាត់កងនឹងប្រាក់រំដោះត្រូវបង់ក្រោយរយៈពេលលើកលែងបន្តពីរឆ្នាំត្រូវបានផុតសុពលភាព ។

៣. សហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញ ក្នុងនោះមាន រោងចក្រវាយនភ័ណ្ឌ រោងចក្រកាត់ដេរ និងរោងចក្រផលិតស្បែកជើង ទាំងអស់ ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរទៅនាយកដ្ឋាន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឱ្យនាយកដ្ឋាននេះកំណត់កាលបរិច្ឆេទ សម្រាប់ការលើកលែង ពន្ធលើប្រាក់ចំណេញបន្ត ដូចមានចែងក្នុងចំណុច១ ខាងលើនេះ ។

អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពន្ធដារ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោក លោកស្រី ជាអ្នកទទួលខុសត្រូវនៃសហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌ បម្រើឱ្យការនាំចេញទាំងអស់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសារាចរណែនាំនេះ ។

នេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង-ស្ថាប័ន
- នាយកដ្ឋានពន្ធដារ
- ឯកសារ-កាលប្បវត្តិ